អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ២ ចេញផ្សាយ ខែកុម្ភៈ ឆ្នាំ២០២២

## សវនកម្មផ្ទៃក្នុង




**សវនកម្មផ្ទៃក្នុង** នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបង្កើតឡើងតាមមាត្រា ៤១ នៃច្បាប់ស្តីពី**សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា** និងអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។ សវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងវាយតម្លៃសកម្មភាពរបស់អង្គភាព ដើម្បីជាជំនួយសម្រាប់ថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សហគ្រាសសាធារណៈ។

**សវនកម្មផ្ទៃក្នុង** ជាការវាយតម្លៃដោយឯករាជ្យលើប្រព័ន្ធគ្រប់គ្រងការដឹកនាំរបស់អង្គភាព ដោយមន្ត្រីរបស់ខ្លួន ដើម្បីឱ្យប្រតិបត្តិការរបស់អង្គភាពមានប្រសិទ្ធភាព សន្សំសំចៃ និងប្រសិទ្ធផលព្រមទាំងទប់ស្កាត់ការខ្ជះខ្ជាយ និងកំហុសអចេតនានៅក្នុងការប្រើប្រាស់ថវិកា និងទ្រព្យសម្បត្តិ។ សវនកម្មផ្ទៃក្នុងក៏ផ្តល់ផងដែរនូវសេវាប្រឹក្សាសំដៅបន្ថែមតម្លៃ និងកែលម្អប្រតិបត្តិការរបស់អង្គភាព និងជួយអង្គភាពឱ្យសម្រេចគោលបំណងដោយប្រើប្រាស់នូវអភិក្រមជាប្រព័ន្ធនិងដោយជំនាញក្នុងការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធផលនៃការគ្រប់គ្រងហានិភ័យដំណើរការត្រួតពិនិត្យ និងអភិបាលកិច្ច។ គោលបំណងចម្បងរបស់សវនកម្មផ្ទៃក្នុងគឺជួយប្រធានសវនដ្ឋានឱ្យបំពេញការងារប្រកបដោយប្រសិទ្ធភាព ដែលជាការទទួលខុសត្រូវរបស់ខ្លួនតាមរយៈផ្តល់ជូននូវការវិភាគ ការវាយតម្លៃ អនុសាសន៍ប្រឹក្សា និងព័ត៌មានទាក់ទងនឹងសកម្មភាពស្ថិតក្រោមការពិនិត្យជាមួយការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងដោយតម្លៃទាបសមរម្យ។

សវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈច្បាប់ និងអនុក្រឹត្យនេះបានចង្អុលបង្ហាញឱ្យបង្កើត នូវអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ដែលមានតួនាទីបំពេញមុខងារជាសេនាធិការជូនក្រុមប្រឹក្សា និងប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។ អង្គភាពសវនកម្មផ្ទៃក្នុងមានបេសកកម្មពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងតាមរយៈការតាមដាន និងការត្រួតពិនិត្យប្រកបដោយជំនាញវិជ្ជាជីវៈក្រមសីលធម៌ ឯករាជ្យភាព សុចរិតភាព ការទទួលខុសត្រូវ និងអភិវឌ្ឍន៍មុខងារសវនកម្មផ្ទៃក្នុង ព្រមទាំង បណ្តុះបណ្តាលអង្គភាពក្រោមឱវាទពាក់ព័ន្ធនឹងមុខងារសវនកម្មផ្ទៃក្នុង។ គោលដៅអង្គភាពសវនកម្មផ្ទៃក្នុងរួមមាន ការពង្រឹងប្រព័ន្ធអភិបាលកិច្ចនិងការគ្រប់គ្រង ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទន់និងរឹង ការកសាងសមត្ថភាពមន្ត្រី ការពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការធ្វើសវនកម្ម ការបញ្ជ្រាបការយល់ដឹងនិងការផ្សព្វផ្សាយ និងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ។

***អត្ថបទៈ*** *កញ្ញា* ***ព្រៀម លីណា***

***ឯកសារយោងៈ***
*១-ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា*
*២-អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។*
*៣-អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ*
*៤-សៀវភៅណែនាំសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*